## រឿងទី៧៖
## ការមានព្រះជន្មរស់ឡើងវិញ

**ខគម្ពីរ៖**
**យ៉ូហាន១១:២៥-២៦**

២៥ ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំហ្នឹងហើយដែលប្រោសមនុស្សអោយរស់ឡើងវិញ ខ្ញុំនឹងផ្ដល់អោយគេមានជីវិត។ អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅហើយក៏ដោយ ក៏នឹងបានរស់ជាមិនខាន។ ២៦ រីឯអស់អ្នកដែលកំពុងតែមានជីវិតនៅរស់ ហើយជឿលើខ្ញុំ មិនស្លាប់សោះឡើយ តើនាងជឿសេចក្ដីនេះឬទេ?»

ក្រោយពេលព្រះយេស៊ូទ្រង់សុគតលើឈើឆ្កាងភ្លាម ពួកសាវ័កបស់ទ្រង់ និងអ្នកដែលដើរតាមព្រះយេស៊ូទាំងអស់មានទុក្ខ សោកជាទម្ងន់។
ចំណែកឯមហាបូជាចារ្យ និងពួកមេដឹកនាំនៃជាតិយូដា ពួកគេបានចាំពាក្យដែលព្រះយេស៊ូមានបន្ទូលពេលទ្រង់នៅមានព្រះជន្មថាទ្រង់នឹងមានព្រះជន្មរស់ឡើងវិញ ដូច្នេះពួកគេបានបញ្ជាឱ្យពួកទាហានយកថ្មដ៏ធំមកបិទមាត់ផ្នូរហើយចាំយាមផ្នូរបស់ព្រះយេស៊ូទាំងយប់ទាំងថ្ងៃ។
នៅថ្ងៃទីបី ក្រោយព្រះយេស៊ូសុគត នាងម៉ារី ជាអ្នកស្រុកម៉ាដាឡា និងនាងម៉ារីជាម្ដាយយ៉ាកុបនិងសាឡូមេ ជាអ្នកដើរតាមព្រះយេស៊ូបានក្រោកពីព្រលឹមទៅផ្នូរដែលមានព្រះសពព្រះយេស៊ូ។ ពួកនាងបាននាំយកគ្រឿងក្រអូបទៅជាមួយ ដើម្បីអប់ព្រះសពព្រះយេស៊ូ។
ពេលទៅដល់ផ្នូរ ពួកនាងឃើញថ្មបានរមៀលចេញពីមាត់ផ្នូរ ឃើញថានៅក្នុងផ្នូរទទេស្អាត។ ពួកនាងរកព្រះសពព្រះយេស៊ូមិនឃើញទាល់តែសោះ។
ប៉ុន្តែ បែរជាឃើញមានទេវតាពាក់សកំពុងអង្គុយនៅកន្លែងដាក់ព្រះសពព្រះយេស៊ូទៅវិញ។
ទេវតានោះមានប្រសាសន៍ទៅពួកស្ត្រីនោះថា៖ «កុំភ័យស្រឡាំងកាំងធ្វើអ្វី! ដ្បិតយើងដឹងថាពួកនាងមករកព្រះយេស៊ូដែលបានឆ្កាងនៅលើឈើឆ្កាងនោះ។ ព្រះយេស៊ូទ្រង់មានព្រះជន្មរស់ឡើងវិញហើយ»។ ស្ត្រីទាំងនោះបាននាំដំណឹងដ៏អំណរនេះរត់ទៅប្រាប់គេឯង។ ពេលកំពុងរត់ទៅ ពួកនាងបានជួបនឹងមនុស្សម្នាក់។ ហើយមនុស្សម្នាក់នោះ គឺជាព្រះយេស៊ូ។
ស្ត្រីទាំងនោះ មានចិត្តអរសប្បាយយ៉ាងខ្លាំង ក៏លុតជង្គង់និងក្រាបចាប់ជើងទ្រង់ហើយគោរពទ្រង់។
នៅល្ងាចថ្ងៃនោះ ពួកសាវ័កទាំងអស់ បានមកប្រជុំគ្នានៅក្នុងបន្ទប់លើដំបូលផ្ទះមួយនៅក្រុងយេរូសាឡឹម។
ពួកគេបានចាក់សោទ្វារយ៉ាងជាប់ ព្រោះខ្លាចពួកទាហានរ៉ូម៉ាំងមកចាប់ពួកគេ។ ពេលនោះ ព្រះយេស៊ូក៏លេចឡើងនៅចំពោះពួកសាវ័កទាំងអស់។
ពេលឃើញព្រះយេស៊ូភ្លាម ពួកសាវ័កទាំងអស់ភ័យតក់ស្លុត ញ័ររន្ធត់យ៉ាងខ្លាំង ព្រោះស្មានតែខ្មោចលង។ ពេលនោះព្រះយេស៊ូក៏មានបន្ទូលថា៖
«ហេតុអ្វីបានជាអ្នករាល់គ្នារន្ធត់ចិត្តដូច្នេះ? អ្នករាល់គ្នាបានឃើញខ្ញុំហើយ តើនៅសង្ស័យពីការមានព្រះជន្មរស់ឡើងវិញរបស់ខ្ញុំទៀតឬ? ចូរអ្នករាល់គ្នាស្ទាបមើល»។ ទីបំផុត ពួកសាវ័កទាំងអស់ ក៏ជឿថាព្រះយេស៊ូពិតជាមានព្រះជន្មរស់ពីសុគតពិតមែន។
ហើយពួកគេក៏បានលុតជង្គង់ថ្វាយបង្គំព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។
ព្រះយេស៊ូបានមានបន្ទូលទៅពួកសាវ័កទាំងអស់ថា៖ «ចូរចេញទៅនាំមនុស្សគ្រប់ជាតិសាសន៍អោយធ្វើជាសិស្ស ហើយធ្វើពិធីជ្រមុជទឹកអោយគេ ក្នុងព្រះនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។ ត្រូវបង្រៀនគេអោយប្រតិបត្តិតាមសេចក្ដីទាំងប៉ុន្មាន ដែលខ្ញុំបានបង្គាប់អ្នករាល់គ្នា។ ចូរដឹងថា ខ្ញុំនៅជាមួយអ្នករាល់គ្នាជារៀងរាល់ថ្ងៃ រហូតដល់អវសានកាលនៃពិភពលោក»។
ព្រះយេស៊ូបានសន្យាថា នៅថ្ងៃចុងក្រោយនៃផែនដីនេះ ទ្រង់នឹងយាងមកម្ដងទៀត ដើម្បីជំនុំជំរះ។







**សកម្មភាពទី១** សូមឆ្លើយនិងសំណួរខាងក្រោម។

a. ក្រោយពីព្រះយេស៊ូបានសោយទីវង្គតហើយ តើពួកមហាបូជាចារ្យ និងពួកអ្នកដឹកនាំបាននឹកឃើញពីព្រះបន្ទូលអ្វី ដែលព្រះយេស៊ូមានបន្ទូល?

---

b. តើស្ត្រីណាខ្លះ ដែលបានឃើញផ្នូររបស់ព្រះយេស៊ូនៅទទេរ?

---

c. សូមអានព្រះគម្ពីរម៉ាថាយ២៨:១៦-២០ រួចឆ្លើយនិងសំណួរ។ តើព្រះយេស៊ូបានបង្គាប់ឱ្យពួកសាវកទ្រង់ធ្វើអ្វី?

---

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញឱ្យចាំ(យ៉ូហាន១១:២៥-២៦)

**២៥ ព្រះយេស៊ូមានព្រះបន្ទូលទៅនាងថា៖ «ខ្ញុំហ្នឹងហើយដែលប្រោសមនុស្សអោយរស់ឡើងវិញ ខ្ញុំនឹងផ្ដល់អោយគេមានជីវិត។ អ្នកណាជឿលើខ្ញុំ ទោះបីស្លាប់ទៅហើយក៏ដោយ ក៏នឹងបានរស់ជាមិនខាន។ ២៦ រីឯអស់អ្នកដែលកំពុងតែមានជីវិតនៅរស់ ហើយជឿលើខ្ញុំ មិនស្លាប់សោះឡើយ តើនាងជឿសេចក្ដីនេះឬទេ?»**

## សកម្មភាពទី២

ស្វែងរកពាក្យ៖ សូមស្វែងរកពាក្យដែលនៅក្នុងតារាងខាងក្រោម។

**រស់ឡើងវិញ ព្រះយេស៊ូ ទេវតា ទីបញ្ចុះសព ស្ត្រីទាំងនោះ ពួកសាវក ម៉ារីជាអ្នកស្រុកម៉ាដាឡា សាឡូម ដំណឹងដ៏រីករាយ ព្រះបន្ទូលព្រះជាម្ចាស់**

| | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចូរ | ព្រះ | បន្ទូល | ព្រះ | ជា | ម្ចាស់ | សោះ | វក | ដាំ | ធំ | ឈឺ | ព្រះ | យេ | ស៊ូ | ថ្នាំ | រាប់ |
| ពិ | ទេវ | យាយ | បាក | កុំ | ទាប | សា | យូរ | គេ | ចោះ | កុ | ខំ | អំ | ច្រ | ន្ទូត | សុំ |
| និ | ប្រ | តា | គំ | យោ | ពូក | រក | ឡូ | អំ | ខ្ពស់ | ឈឺ | ថ្មម | ត្រង់ | ក្រ | លេង | មា |
| រឿង | លំ | យេ | រក្សា | បស់ | ចូរ | រាវ | ជ្រៅ | មេ | ស្រ | ឡា | មើល | ខ្លាំង | រស់ | ខ្វះ | ជា |
| ទាន | ដាប់ | ព្រះ | ម៉ា | រី | ជា | អ្នក | ស្រុក | ម៉ា | ដា | ឡា | លេង | ឈឺ | ម៉េ | ឡើង | ឃុំ |
| ទាំ | ចូល | បន្ទូល | ថៃ | ទាំង | ចេះ | សម | ៃ | គំ | ក្តី | គូ | ៃ | សព | អ្នក | ធ្លាប់ | វិញ |
| ផារ | ក្នុង | នោះ | លូត | ប្រ | ឆា | បាច់ | ចាំ | ហាំ | មេ | ចាំ | បញ្ចុះ | ប្រា | ក្រី | បើក | ខំ |
| រាំ | ទាំង | ខ្សត់ | ជុះ | គំ | ណើ | បើង | ទ្រាំ | ដៃ | បិ | ទី | ថ្ងៃ | ចង់ | ជា | ទ្វារ | បុ |
| ស្ត្រី | សង់ | អត់ | នើប | ដី | ដំ | ណឹង | ដំ | រីក | រាយ | ប្រ | តិ | បី | ធំ | ស្ពាន | សួរ |